## Asking "How do you write this?"



១ ពិសិដ្ឋ៖ វាសនា ស្គាល់ពាក្យថា និវាសដ្ឋាន អត់? មានន័យថាម៉េច?
វាសនា៖ ពាក្យអីគេ? សរសេរម៉េច?
ពិសិដ្ឋ៖ សរសេរអញ្ចេក។
វាសនា៖ និវាសដ្ឋាន? ដឹងតែ -ដ្ឋាន... -ដ្ឋាន សំដៅលើទីកន្លែង។ ឆែកវចនានុក្រមសិន។

២ ពិសិដ្ឋ៖ វាសនា ដឹងពាក្យថា ព័ត៌មាន សរសេរម៉េចអត់?
ខ្ញុំទើបតែដឹងថាខ្លួនឯងរាល់ដងសរសេរខុស។
វាសនា៖ សរសេរអក្សរ ព សំយោគសញ្ញា ត ម ស្រៈអា និង ន។ អីចឹងមែន? ត្រូវអត់?
ពិសិដ្ឋ៖ ខុសហើយ។ នៅលើ ត មាន របាទមួយទៀត។
វាសនា៖ ហ្នឹង? អត់ដែលដឹងសោះ។

៣ ពិសិដ្ឋ៖ វាសនា បោះពុម្ព សរសេរម៉េចទៅ? ក្រោមអក្សរ ម ជើង ភ ឬក៏ ជើង ព?
វាសនា៖ ជើង ព មិនមែនជើង ភ អេ៎។

៤ អ្នកចុះឈ្មោះ៖ ឈ្មោះអីដែរ?
ពិសិដ្ឋ៖ ចាន់ ពិសិដ្ឋ។
អ្នកចុះឈ្មោះ៖ ចាន់ ហ្នឹង ព្រះចន្ទ ហ្នឹងមែន? ប្រកបឲ្យតិច បានអេ៎?
ពិសិដ្ឋ៖ មិនមែន ព្រះចន្ទ អេ៎។ ច ស្រៈអា ន បន្តក់ ធម្មតា។

| | |
|---|---|
| ពិសិដ្ឋ, វាសនា | male Cambodian names |
| និវាសដ្ឋាន | = ទីលំនៅ = ផ្ទះ = residence, house |
| [ពាក្យ]អីគេ? | What [word]? |
| អញ្ចេក | alternative pronunciation of អញ្ចេះ = like this |
| ឆែកវចនានុក្រម | to look up in the dictionary; also: រកមើលក្នុង/បើកវចនានុក្រម |
| សំយោគសញ្ញា | the diacritical mark ◌័ used in Sanskrit and Pali words |
| របាទ | the diacritical mark ◌៌ used in Sanskrit and Pali words |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| អត់ដែលដឹងសោះ | I've never known that! |
| បោះពុម្ព | to publish, to print |
| អេ៎ | spoken form of the negation or question particle ទេ |
| ចុះឈ្មោះ | to register one's name, to enlist, enroll |
| ប្រកប | to spell |
| បន្តក់ | the diacritical mark ៉ placed over a final consonant of a syllable to indicate that the preceding vowel is shortened |

## Cultural notes

តួអក្សរខ្មែរកើតឡើងដោយការផ្គុំព្យញ្ជនៈ ស្រៈ ជើង និង សញ្ញាផ្សេងៗ។
តួអក្សរខ្លះមិនមានសំឡេងនៅក្នុងពេលអាននោះទេ ដូចជា រ ជាដើម ដូច្នេះ
សូម្បីជនជាតិខ្មែរក៏មានការលំបាកក្នុងការចងចាំអក្ខរាវិរុទ្ធទាំងអស់ផងដែរ
ហើយត្រូវប្រុងប្រយ័ត្ននៅពេលសរសេរឈ្មោះ ព្រោះអាចមានពាក្យសូរដូច។

| | |
|---|---|
| អក្ខរាវិរុទ្ធ | spelling, orthography |
| ពាក្យសូរដូច | homophone (words with the same pronunciation but different spellings) |

## Additional dialogue

៥ ពិសិដ្ឋ៖ ពន្ធធនាគារ? បានន័យថា គុក ហ្នឹងមែន? ម៉េចសរសេរអីចឹងវិញ?
វាសនា៖ បើមិនសរសេរអីចឹង សរសេរម៉េចវិញ?
ពិសិដ្ឋ៖ អត់មាន ធ អេ៎។ ពន្ធ ហើយ -នាគារ យកម៉ង។

៦ ពិសិដ្ឋ៖ វាសនា ជួយមើលពាក្យ សម្បជញ្ញៈ សរសេរត្រូវអត់?
វាសនា៖ ត្រូវតាស។
ពិសិដ្ឋ៖ ចុះពាក្យ គិលានុប្បដ្ឋាយិកា សរសេរអីចឹងត្រូវអេ៎?
វាសនា៖ មិនមែនទេដឹង។ ខ្ញុំគិតថាអត់មានជើង ប អេ៎។

| | |
|---|---|
| ពន្ធនាគារ = គុក | jail, prison; also: មន្ទីរឃុំឃាំង |
| បើមិនសរសេរអីចឹង សរសេរម៉េចវិញ? | If it's not spelled like this, then how is it spelled? |
| យកម៉ង | spoken form of យកតែម្តង = directly, right away |
| សម្បជញ្ញៈ | conscience, consciousness |
| គិលានុបដ្ឋាយិកា | female nurse |
| មិនមែនទេដឹង | I don't think so |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.